ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ : ២៤ អយក.សណន

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៤

**សេចក្តីណែនាំ**
**ស្តីពី**
**ការបង្រៀននិងរៀនមុខវិជ្ជាភាសាអង់គ្លេសនៅសាលាបឋមសិក្សា**

**យោង** : - ប្រកាសលេខ២៤៦៧ អយក.ប្រក.ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការអនុញ្ញាត ឱ្យបោះពុម្ពផ្សាយឯកសារកម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសសម្រាប់បឋមសិក្សាថ្នាក់ទី៤ ទី៥ និងទី៦
- ប្រកាសលេខ៣០៩៣អយក.ប្រក.ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការអនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅភាសាអង់គ្លេសថ្នាក់ទី៤ ។

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់បញ្ចូលមុខវិជ្ជាភាសាអង់គ្លេសក្នុងកម្មវិធីសិក្សា នៅកម្រិតបឋមសិក្សាចំណេះទូទៅ ពីថ្នាក់ទី៤ឡើងទៅ ដើម្បីផ្តល់ឱកាសឱ្យសិស្សបានសិក្សាជាមូលដ្ឋានដំបូងនៃភាសាអង់គ្លេសសម្រាប់ជាគ្រឹះក្នុងការបន្តការសិក្សានៅកម្រិតមធ្យមសិក្សា។

ដើម្បីអនុវត្តកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលភាសាអង់គ្លេសឱ្យមានប្រសិទ្ធភាព ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដូចតទៅៈ

១. ការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេស

គ្រប់គ្រឹះស្ថានសិក្សា បឋមសិក្សាចំណេះទូទៅសាធារណៈទាំងអស់ ត្រូវប្រើប្រាស់សៀវភៅភាសាអង់គ្លេស "ENGLISH GRADE4" ជាសៀវភៅសិក្សាគោល ក្នុងការរៀននិងបង្រៀននៅថ្នាក់ទី៤។

២. ការប្រើប្រាស់ម៉ោងសិក្សា

ការបង្រៀននិងរៀនភាសាអង់គ្លេសនេះ ត្រូវបែងចែកម៉ោងច្បាស់លាស់ ក្នុងកាលវិភាគប្រចាំសប្តាហ៍ដោយអនុវត្ត០២ម៉ោងសិក្សាក្នុងមួយសប្តាហ៍ ហើយមួយម៉ោងសិក្សា មានរយៈពេល៤០នាទី។

៣. ការប្រើប្រាស់ធនធានគ្រូបង្រៀន

គណៈគ្រប់គ្រងសាលារៀនត្រូវជ្រើសរើសយកគ្រូបង្រៀន ដែលចេះភាសាអង់គ្លេស សម្រាប់បង្រៀនមុខវិជ្ជាភាសាអង់គ្លេសនៅថ្នាក់ទី៤ ហើយសមាសភាពគ្រូបង្រៀនទាំងនោះ ជាមុខសញ្ញាក្នុងការទទួលការបណ្តុះបណ្តាលជំនាញឬបំប៉នសមត្ថភាពផ្នែកភាសាអង់គ្លេស នៅពេលអនាគត ។/.

៤. ការកំណត់ពិន្ទុ

ការដាក់ពិន្ទុ ត្រូវធ្វើការវាយតម្លៃលើសមាសភាគទាំងបួននៃភាសាអង់គ្លេសគឺ ការស្តាប់ ការនិយាយ ការអាន និងការសរសេរ ដែលពិន្ទុសរុបគឺ១០ពិន្ទុ ដូចមុខវិជ្ជាដទៃទៀតដែរ ។

ទទួលសេចក្តីណែនាំនេះ គ្រប់អង្គភាពថ្នាក់កណ្តាល រាជធានី- ខេត្ត គ្រឹះស្ថានអប់រំ ត្រូវចាត់ចែងអនុវត្តជាកំហិត និងត្រូវធ្វើការផ្សព្វផ្សាយបន្តតាមអង្គភាពក្រោមឱវាទ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិត ហង់ ជួន ណារ៉ុន